ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

# កម្មវិធីសិក្សាលម្អិត
# បំណិនជីវិតតាមមូលដ្ឋាន

## សម្រាប់បឋមសិក្សា

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

ឆ្នាំ ២០១១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៤០៩១ អយក.ប្រក

**ប្រកាស**
**ស្តីពី**
**ការអនុញ្ញាតឱ្យបោះពុម្ពផ្សាយឯកសារ**
**"កម្មវិធីសិក្សាលម្អិតបំណិនជីវិតតាមមូលដ្ឋាន សម្រាប់បឋមសិក្សា"**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដាឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
-បានឃើញអនុក្រឹត្យលេខ៨៤អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
-យោងគោលនយោបាយសម្រាប់អភិវឌ្ឍន៍កម្មវិធីសិក្សាចំណោះទូទៅ២០០៥-២០០៩
-យោងសេចក្តីណែនាំលេខ៣៨៤២ អយក.សណន. ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០០ របស់ក្រសួងអប់រំ យុវជននិង កីឡា ស្តីពីប្រព័ន្ធអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស
-យោងសំណើរបស់ប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១១
-យោងរបាយការណ៍ពិគ្រោះយោបល់ស្តីពី " កម្មវិធីសិក្សាលម្អិតបំណិនជីវិតតាមមូលដ្ឋាន និងសេចក្តីណែនាំអនុវត្តន៍" ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ២០១១
-តាមសំណើរបស់ប្រធានក្រុមប្រឹក្សាអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស

**សម្រេច**

ប្រការ១ - អនុញ្ញាតឱ្យបោះពុម្ពផ្សាយឯកសារ" កម្មវិធីសិក្សាលម្អិតបំណិនជីវិតតាមមូលដ្ឋានសម្រាប់បឋមសិក្សា" ដែលរៀបចំដោយនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាដើម្បីប្រើប្រាស់នៅតាមសាលាបឋមសិក្សាចំណោះទូទៅ ។

ប្រការ២-- អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងនាយកដ្ឋានបឋមសិក្សាមានភារកិច្ចអនុវត្តប្រកាសនេះ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ២០១១

អ៊ឹម_សិទ្ធី

កន្លែងទទួល:
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
" ដើម្បីជូនជ្រាបជាព័ត៌មាន"
ដូចប្រការ២
កាលប្បវត្តិ- ឯកសារ..អកស.

អាសយដ្ឋានលេខ៨០ មហាវិថីព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៧ ២៥៣ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ៤២៧ ៣៥៦ / ៤២៦ ៩៥១ / ២១២ ៥១២
E-mail: crsmeys@camnet.com.kh / yangyano@camnet.com.kh Web Site: www.moeys.gov.kh

# កថាមុខ

ការរីកចម្រើននៃបច្ចេកវិទ្យាទំនើប បានធ្វើឱ្យប្រទេសនៅក្នុងសកលលោកខិតខំ ពង្រឹងមូលដ្ឋានអប់រំ និង គុណភាពអប់រំ ពិសេសការបណ្តុះបណ្តាលធនធានមនុស្សប្រកបដោយគុណភាព និង មានជំនាញច្បាស់លាស់ ។

ឆ្លើយតបនឹងតម្រូវការចាំបាច់ក្នុងការអភិវឌ្ឍប្រទេសជាតិឱ្យរីកចម្រើន ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ក្រសួងអប់រំ យុវជន និង កីឡា បានបង្កើតគោលនយោបាយសម្រាប់អភិវឌ្ឍកម្មវិធីសិក្សាចំណេះទូទៅដែលមានបញ្ចូលកម្មវិធីសិក្សា បំណិនជីវិតតាមមូលដ្ឋាន។

ការកែលម្អគុណភាពអប់រំនឹងផ្តល់ឱ្យសិស្សនូវចំណេះដឹងមូលដ្ឋាន ជំនាញផ្សេងៗ និងបទពិសោធល្អៗចាំបាច់សម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃ។ឯកសារកម្មវិធីសិក្សាលម្អិតបំណិនជីវិតតាមមូលដ្ឋានសម្រាប់បឋមសិក្សាជាមូលដ្ឋានគ្រឹះសម្រាប់ការប្រើប្រាស់ក្នុងគ្រប់ស្ថានភាពនៃជីវិតរស់នៅរបស់សិស្សានុសិស្សដើម្បីលើកកម្ពស់ជីវភាពគ្រួសារ និង ជាឯកសារជំនួយដល់សាលារៀន សហគមន៍ និងដៃគូអភិវឌ្ឍន៍នានាក្នុងការរៀបចំដំណើរការអនុវត្តបំណិនជីវិតតាមមូលដ្ឋានប្រកបដោយនិរន្តរភាព និងប្រសិទ្ធភាព។

ដូច្នេះការអភិវឌ្ឍកម្មវិធីសិក្សាលម្អិតបំណិនជីវិតតាមមូលដ្ឋានសម្រាប់បឋមសិក្សាជាផ្នែកមួយក្នុងការលើកកម្ពស់គុណភាព ប្រសិទ្ធភាព និង និរន្តរភាពក្នុងវិស័យអប់រំ។

ក្រសួងអប់រំ យុវជន និងកីឡាសង្ឃឹមថាសាលារៀន សហគមន៍ ដៃគូអភិវឌ្ឍន៍នឹងជំរុញការអនុវត្តកម្មវិធីសិក្សានេះឱ្យសម្រេចគោលដៅអប់រំសម្រាប់ទាំងអស់គ្នាស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា និង សូមថ្លែងអំណរគុណចំពោះ អង្គការយូនីសេហ្វ និង ក្រុមការងារអភិវឌ្ឍកម្មវិធីសិក្សាក្នុងការខិតខំប្រឹងប្រែងអភិវឌ្ឍឯកសារដ៏ មានសារៈសំខាន់នេះ ។៕

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**អ៊ឹម សិទ្ធី**

## គណៈកម្មការគ្រប់គ្រង

លោកជំទាវ ទន់ សាអ៊ីម
ឯកឧត្តម អ៊ូ អេង
លោក អេង គឹមលី

## គណៈកម្មការរៀបរៀង

លោក ព្រំ វិបុល | លោក ឈុំ វណ្ណធន

## គណៈកម្មការនិពន្ធ

| | | | |
|---|---|---|---|
| លោកស្រី | ហ៊ុយ ចន្ទូ | លោក | មាស ជុតិមា |
| លោក | សូរ ច័ន្ទបូរី | លោក | ងិន សុតារា |
| លោកស្រី | ទេព ប៉ុណ្ណារី | លោកស្រី | ប៉ែន នាង |

## គណៈកម្មការពិនិត្យ

| | | | |
|---|---|---|---|
| លោក | អេង គឹមលី | លោក | ស៊ុន ប៊ុណ្ណា |
| លោកស្រី | អ៊ុក សុមនី | លោក | យិន ធី |

## គណៈកម្មការវាយកុំព្យូទ័រ និងរចនា

| | | | |
|---|---|---|---|
| លោកស្រី | ឡៀប ផល្លី | លោក | ឡុង សុវណ្ណា |

# អារម្ភកថា

*គោលនយោបាយសម្រាប់អភិវឌ្ឍកម្មវិធីសិក្សាចំណេះទូទៅ២០១០ - ២០១៤ របស់ក្រសួងអប់រំ យុវជន និងកីឡាបានបញ្ចូលការអប់រំបំណិនជីវិតទៅក្នុងកម្មវិធីសិក្សា ជាតិ នៅកម្រិត បឋមសិក្សា និងមធ្យមសិក្សា ។*

*ឯកសារកម្មវិធីសិក្សាលម្អិតបំណិនជីវិតតាមមូលដ្ឋានសម្រាប់បឋមសិក្សា រៀបចំឡើងទាក់ទងទៅនឹងប្រធានបទ ដែលជាតម្រូវការរបស់មូលដ្ឋាន ។ កម្មវិធីសិក្សានេះរួមមាន ប្រធានបទដែលទាក់ទងនឹងបំណិនកសិកម្ម សេវាកម្ម និង សិប្បកម្មខ្នាតតូច។ ឯកសារនេះជួយនាយកសាលារៀន គ្រូបង្រៀនក្នុងការជ្រើសរើសប្រធានបទ លំនាំ រៀបចំកាលវិភាគ វិធីសាស្ត្របង្រៀន និងរៀន និងវាយតម្លៃសម្រាប់អនុវត្តកម្មវិធីបំណិនជីវិត តាមមូលដ្ឋាន ថ្នាក់ទី៤ ទី៥ និងទី៦ ប្រកបដោយប្រសិទ្ធភាព និងមាននិរន្តរភាព និងផ្តល់ឱកាសឱ្យសិស្សក្នុងការអភិវឌ្ឍបំណិន ដើម្បីរស់នៅប្រកបដោយសុខុមាលភាពនៅក្នុងសង្គម។*

*គណៈកម្មការនិពន្ធរង់ចាំទទួលរាល់មតិយោបល់កែលម្អពីគ្រប់មជ្ឈដ្ឋានដើម្បីរួមចំណែកក្នុងការ ធ្វើឱ្យឯកសារនេះកាន់តែមានប្រសិទ្ធភាពខ្ពស់ ។*

*គណៈកម្មការនិពន្ធ*

# មាតិកា


កថាមុខ..........i

គណៈកម្មការ..........ii

អារម្ភកថា..........iii

សារតារ..........1

គោលបំណង..........1

ផ្នែកទី១ ៖កម្មវិធីសិក្សាលម្អិតបំណិនជីវិតតាមមូលដ្ឋាន..........3

១.លទ្ធផលសិក្សាថ្នាក់ទី៤ដល់ទី៦..........4

២.បញ្ជីប្រធានបទថ្នាក់ទី៤..........7

៣.បញ្ជីប្រធានបទថ្នាក់ទី៥..........8

៤.បញ្ជីប្រធានបទថ្នាក់ទី៦..........9

ផ្នែកទី២៖ សេចក្ដីណែនាំអនុវត្តន៍កម្មវិធីសិក្សាលម្អិតបំណិនជីវិតតាមមូលដ្ឋាន..........11

១.ការជ្រើសរើសប្រធានបទបំណិនជីវិត និងការកសាងម៉ូឌុល..........12

ក.ការជ្រើសរើសប្រធានបទ..........12

ខ.ការកសាងម៉ូឌុល..........13

២.ការរៀបចំកាលវិភាគ..........15

៣.វិធីសាស្ត្របង្រៀន និងដំណើរការបង្រៀន..........16

៤.ការវាយតម្លៃ..........18

❖ **សារតារ**

ប្រទេសជាច្រើនលើសកលលោក រួមទាំងប្រទេសកម្ពុជាផងដែរ កំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងលើការបង្រៀនបំណិនជីវិត ដើម្បីឱ្យអ្នកសិក្សាមានចំណេះដឹង បំណិនអភិវឌ្ឍខ្លួនឱ្យក្លាយជាពលរដ្ឋល្អ ពលករជំនាញនិងចេះរស់នៅជាមួយគ្នា ។

នៅខែធ្នូ ឆ្នាំ ២០០៤ ក្រសួងអប់រំ យុវជន និងកីឡា បានអនុញ្ញាតឱ្យប្រើប្រាស់ជាផ្លូវការនូវគោលនយោបាយសម្រាប់អភិវឌ្ឍន៍កម្មវិធីសិក្សាចំណេះទូទៅ ២០០៥-២០០៩។ គោលនយោបាយនេះត្រូវបានបញ្ចូលការអប់រំបំណិនជីវិត ដែលផ្ដល់ឱ្យសិស្សនូវបំណិនជីវិតបានកំណត់ថា " សាលារៀនត្រូវបង្កើតភាពជាដៃគូជាមួយមាតាបិតា សហគមន៍មូលដ្ឋាន អង្គការសហគមន៍ និងដៃគូអភិវឌ្ឍន៍ ហើយត្រូវអភិវឌ្ឍកម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋាន ដែលមានពី ២ ទៅ ៥ម៉ោងសិក្សាក្នុងមួយសប្ដាហ៍ ដែលមួយម៉ោងសិក្សាមានរយៈពេល៤០នាទីសម្រាប់បឋមសិក្សា និង៥០នាទីសម្រាប់មធ្យមសិក្សា ដើម្បីជួយបំពេញកម្មវិធីសិក្សាជាតិ "។

ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយសម្រាប់អភិវឌ្ឍន៍កម្មវិធីសិក្សាចំណេះទូទៅ ក្រសួងអប់រំ យុវជន និងកីឡាបានបង្កើតគោលនយោបាយអប់រំបំណិនជីវិតឆ្នាំ២០០៦ ដែលអាចអនុវត្តបានទាំងការអប់រំក្នុងប្រព័ន្ធនិងក្រៅប្រព័ន្ធ ។ គោលនយោបាយអប់រំបំណិនជីវិតឆ្នាំ២០០៦ បានកំណត់អំពីនិយមន័យបំណិនជីវិត និង ប្រភេទបំណិនជីវិត។

បំណិនមូលដ្ឋានត្រូវបង្រៀនដល់អ្នកសិក្សាទាំងអស់ ដោយបញ្ជ្រាបចូលតាមមុខវិជ្ជាសំខាន់ៗទាំងបួន ( ភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ និង សិក្សាសង្គម ) ដែលជាកម្មវិធីសិក្សាជាតិ។

បំណិនអាជីព ជាបំណិនទាំងឡាយណាដែលផ្ដោតលើសមត្ថភាពវិជ្ជាជីវៈជាក់ស្ដែង ហើយចែកជាពីរផ្នែកទៀតគឺបំណិនអាជីពងាយ និង បំណិនវិជ្ជាជីវៈ។បំណិនអាជីពងាយបង្រៀននៅក្នុងកម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋានពីថ្នាក់ទី ១ ដល់ទី ១០ហើយបំណិនវិជ្ជាជីវៈគឺ បង្រៀននៅក្នុងកម្មវិធីអប់រំវិជ្ជាជីវៈជម្រើសសម្រាប់ថ្នាក់ទី១១និង១២។

ក្រសួងអប់រំ យុវជន និងកីឡាបានផ្ដល់អាទិភាពដល់សាលារៀនក្នុងការអនុវត្តកម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋាន ដោយសហការជាមួយដៃគូអភិវឌ្ឍន៍ សហគមន៍មូលដ្ឋាននិងអ្នកពាក់ព័ន្ធ ។ ក្នុងការអនុវត្តជាក់ស្ដែង សាលារៀនជួបការលំបាកជាច្រើន ហើយសមត្ថភាពយល់ដឹងចំពោះកម្មវិធីសិក្សាបំណិនជីវិតនៅមានកម្រិត។ បញ្ហាប្រឈមក្នុងការអនុវត្តនេះ បណ្ដាលមកពីការខ្វះគ្រូឯកទេសបំណិនជីវិត ខ្វះថវិកា ខ្វះកម្មវិធីសិក្សា និងខ្វះសៀវភៅសិស្ស ។

ដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងការអនុវត្តជាក់ស្ដែងខាងលើក្រសួងអប់រំ យុវជន និងកីឡាបានអភិវឌ្ឍឯកសារជាច្រើន ដើម្បីជាជំនួយដល់សាលារៀនមានដូចជា

- **ឯកសារការណែនាំស្តីពីការអនុវត្តកម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋាន សម្រាប់សាលារៀន សហគមន៍ និងអង្គការក្រៅរដ្ឋាភិបាល** គឺជាឯកសារជំនួយដល់អ្នកពាក់ព័ន្ធទាំងឡាយ ដើម្បីអនុវត្តកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន ដោយបានបង្ហាញអំពីរបៀបនៃការអនុវត្តនៅឆ្នាំ២០០៦។
- **ឯកសារកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន** គឺជាឯកសារជំនួយដល់គ្រូបង្រៀនបំណិនជីវិត ដែលមានចំនួន ២០ម៉ូឌុល ជាឧទាហរណ៍ សម្រាប់ជ្រើសរើសនៅឆ្នាំ ២០០៦ ។
- **ឯកសារលំណែនាំការអប់រំបំណិនជីវិតតាមមូលដ្ឋាន** បានបកស្រាយ លំនាំបង្រៀន និងរៀនបំណិនជីវិតតាមមូលដ្ឋាន លើមេរៀន ស្តីពីការដាំដុះ និងចិញ្ចឹម ដើម្បីឱ្យសិស្សក្លាយជាអ្នកផលិត ។

❖ **គោលបំណង**

ឯកសារកម្មវិធីសិក្សាលម្អិតបំណិនជីវិតតាមមូលដ្ឋាន និង សេចក្តីណែនាំអនុវត្តន៍ បានកសាងឡើង ដើម្បី ៖

- បង្កភាពងាយស្រួលដល់សាលារៀនបឋមសិក្សាក្នុងការអនុវត្តកម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋាន
- ផ្តល់ការណែនាំអំពីរបៀបជ្រើសរើសប្រធានបទ និង ការរៀបចំកម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋាន
- ផ្តល់អំពីលំនាំ និង របៀបរៀបចំកាលវិភាគ
- ផ្តល់អំពីលំនាំនៃវិធីសាស្ត្របង្រៀន និងរៀន និងវាយតម្លៃ
- លើកទឹកចិត្តអ្នកពាក់ព័ន្ធឱ្យផ្តោតការយកចិត្តទុកដាក់ចំពោះតម្រូវការដែលមាននៅក្នុងសហគមន៍ និង ចូលរួមចំណែកអភិវឌ្ឍប្រទេសជាតិ ។

# ផ្នែកទី ១
# កម្មវិធីសិក្សាលម្អិត
# បំណិនជីវិតតាមមូលដ្ឋាន

## ១. លទ្ធផលសិក្សាថ្នាក់ទី៤ដល់ទី៦

| ប្រធានបទ | លទ្ធផលសិក្សា |
|---|---|
| កសិកម្ម<br>ការដាំដំណាំ<br>(មើម ដើម<br>ស្លឹក ផ្លែ) | • ធ្វើគម្រោងដាំដំណាំមើម ដើម ស្លឹក ផ្លែបានត្រឹមត្រូវ<br>• ប្រាប់ឧបករណ៍សម្រាប់ប្រើប្រាស់ក្នុងការដាំដំណាំមើម ដើម ស្លឹក ផ្លែ<br>• ជ្រើសរើសពូជសម្រាប់ដាំដំណាំមើម ដើម ស្លឹក ផ្លែ<br>• ជ្រើសរើសដីឱ្យបានត្រឹមត្រូវសម្រាប់ដាំដំណាំមើម ដើម ស្លឹក ផ្លែទៅតាមលក្ខណៈបច្ចេកទេស<br>• រៀបចំដីសម្រាប់ដាំដំណាំតាមប្រភេទនីមួយៗបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស<br>• ជ្រើសរើសនិងប្រើប្រាស់ជីឱ្យបានត្រឹមត្រូវ ជាពិសេសជីធម្មជាតិ ឬ ជីកំប៉ុស្ត<br>• ដាំដំណាំមើម ដើម ស្លឹក ផ្លែបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស<br>• ថែទាំដំណាំមើម ដើម ស្លឹក ផ្លែបានត្រឹមត្រូវ<br>• សង្កេត និងតាមដានការលូតលាស់របស់ដំណាំ<br>• កំណត់ពេលវេលាប្រមូលផលបានត្រឹមត្រូវ<br>• បង្ហាញពីប្រយោជន៍នៃដំណាំមើម ដើម ស្លឹក ផ្លែបានត្រឹមត្រូវ និង របៀបកែច្នៃធ្វើជាអាហារផ្សេងៗ<br>• ផ្សព្វផ្សាយ និងពង្រីកការដាំដំណាំមើម ដើម ស្លឹក ផ្លែបានត្រឹមត្រូវតាមគ្រួសារ និងសហគមន៍<br>• មានចំណូលចិត្តក្នុងការដាំដំណាំ។ |
| កសិកម្ម<br>ការចិញ្ចឹមសត្វ | • ធ្វើគម្រោងចិញ្ចឹមសត្វបានត្រឹមត្រូវ<br>• ជ្រើសរើសពូជសត្វយកមកចិញ្ចឹមបានត្រឹមត្រូវ<br>• ជ្រើសរើសកន្លែងសម្រាប់ធ្វើជម្រកចិញ្ចឹមសត្វបានល្អ<br>• ផ្តល់ចំណីអាហារបានត្រឹមត្រូវ<br>• រៀបរាប់ប្រភេទចំណីសម្រាប់សត្វ<br>• ថែទាំសត្វចិញ្ចឹមបានល្អត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស<br>• សង្កេត និង តាមដានការធំធាត់របស់សត្វចិញ្ចឹម ធ្វើអនាម័យជម្រកសត្វជាប្រចាំ<br>• ប្រាប់និងអនុវត្តវិធីការពារសុវត្ថិភាពក្នុងពេលអនុវត្តការងារ<br>• រៀបរាប់ផលប្រយោជន៍នៃសត្វនីមួយៗ<br>• ស្រឡាញ់ និង ចូលចិត្តចិញ្ចឹមសត្វ។ |

| ប្រធានបទ | លទ្ធផលសិក្សា |
| --- | --- |
| **សេវាកម្ម**<br>ថ្នាក់ទី ៤ | • រៀបចំប្រដាប់ប្រដាប្រើប្រាស់ក្នុងគេហដ្ឋាន និង ថ្នាក់រៀនរបស់ខ្លួនឱ្យមានសណ្ដាប់ធ្នាប់<br>• បង្ហាញពីសារប្រយោជន៍នៃការធ្វើអនាម័យនិងសណ្ដាប់ធ្នាប់ក្នុងគេហដ្ឋាន និង ថ្នាក់រៀនរបស់ខ្លួន<br>• មានអាកប្បកិរិយា សំដីសមរម្យចំពោះភ្ញៀវ<br>• សង្កេត និង អនុវត្តបានការរក្សាសណ្ដាប់ធ្នាប់<br>• ថែរក្សាបរិស្ថាន និងសុវត្ថិភាពចំណី អាហារ ។ |
| **សេវាកម្ម**<br>ថ្នាក់ទី ៥ | • កំណត់ប្រភេទផ្កា ថូ ឬ កន្ត្រកដែលត្រូវរៀបចំឱ្យមានសោភ័ណ<br>• មានគំនិតលក់នំចំណី ឬ សម្ភារៈតាមតម្រូវការភ្ញៀវ<br>• ប្រាប់បានពីរបៀបទទួលភ្ញៀវឱ្យបានសមរម្យ<br>• រៀបរាប់ពីរបៀបរៀបចំតុអាហារ<br>• សំដែងឥរិយាបថសមរម្យថ្លៃថ្នូរ ក្នុងការទទួលភ្ញៀវ<br>• ថែរក្សាអនាម័យ និង បរិស្ថាន។ |
| **សេវាកម្ម**<br>ថ្នាក់ទី ៦ | • រៀបចំទុកដាក់ និងសម្អាតសម្ភារៈប្រើប្រាស់ឱ្យមានអនាម័យ និងសោភ័ណភាព<br>• ជ្រើសរើសវត្ថុផ្សេងៗមកធ្វើជាវត្ថុអនុស្សាវរីយ៍សម្រាប់លក់<br>• ក្រងភួងផ្កាបានស្អាត<br>• បត់កន្សែងបង្កើតជារូបផ្សេងៗបានស្អាត និងត្រឹមត្រូវ<br>• ច្នៃប្រឌិតធ្វើចំណីអាហារដែលអាចទុកបានរយៈពេលយូរ<br>• ឱ្យតម្លៃទៅលើវត្ថុប្រើប្រាស់ដែលផលិតក្នុងស្រុក។ |

| ប្រធានបទ | លទ្ធផលសិក្សា |
|---|---|
| **សិប្បកម្ម** ថ្នាក់ទី៤ | • កំណត់សម្ភារៈ វត្ថុធាតុដើមសម្រាប់ផលិតសម្ភារៈប្រើប្រាស់(អំបោស វត្ថុអនុស្សាវរីយ៍)<br>• ប្រាប់គ្រឿងផ្សំសម្រាប់យកមកផលិតទឹកខ្មេះ<br>• ជ្រើសរើសរូបដែលត្រូវធ្វើអំពីក្រដាស<br>• សង្កេត និងអនុវត្តការកាត់បត់ក្រដាសធ្វើស្រោមសំបុត្រនិងរូបផ្សេងៗ<br>• បណ្តុះស្មារតីសិស្សឱ្យស្រឡាញ់ការងារសិប្បកម្ម និងមានគំនិតច្នៃប្រឌិតក្នុងការផលិតវត្ថុផ្សេងៗ។ |
| **សិប្បកម្ម** ថ្នាក់ទី ៥ | • កំណត់រូបភាព ឬ ព្រាងគំនូរដែលត្រូវបិទក្រដាសពណ៌<br>• កាត់បិទក្រដាសពណ៌ធ្វើជារូបធរណីមាត្រ(ការេ ចតុកោណកែង ត្រីកោណ រង្វង់)<br>• ត្បាញកន្ទេលពីក្រដាសពណ៌<br>• ផលិតប្រអប់ដាក់វត្ថុអនុស្សាវរីយ៍ពីក្រដាសកាតុងនិងរចនាឱ្យមានសោភ័ណ<br>• ផលិតវត្ថុអនុស្សាវរីយ៍អំពីវល្លិ រពាក់ ស្លឹកត្នោតឱ្យបានល្អនិងស្អាត<br>• កំណត់សម្ភារៈ និងគ្រឿងផ្សំសម្រាប់យកមកធ្វើជ្រក់<br>• ថែរក្សាអនាម័យនិងស្រឡាញ់ការងារសិប្បកម្ម។ |
| **សិប្បកម្ម** ថ្នាក់ទី៦ | • កំណត់រូបភាព ឬ ទម្រង់វត្ថុផ្សេងៗដែលត្រូវធ្វើ<br>• សង្កេត និង អនុវត្តបានពីរបៀបធ្វើ<br>• កំណត់សម្ភារៈ វត្ថុធាតុដើម និង គ្រឿងផ្សំដែលត្រូវយកមកប្រើប្រាស់<br>• មានគំនិតច្នៃប្រឌិតក្នុងការផលិតសម្ភារៈប្រើប្រាស់ផ្សេងៗ<br>• ថែរក្សា និង សន្សំសំចៃ សម្ភារៈវត្ថុធាតុដើមសម្រាប់ផលិតដោយយកចិត្តទុកដាក់<br>• មានចំណូលចិត្តក្នុងការផលិត និង លើកកម្ពស់ផលិតផលក្នុងស្រុក<br>• ប្រាប់ពីសារប្រយោជន៍របស់ផលិតផលដែលបានផលិតរួច |

## ២.បញ្ជីប្រធានបទថ្នាក់ទី៤

| ប្រធានបទ | ម៉ោង | | |
|---|---|---|---|
| | ទ្រឹស្តី | អនុវត្ត | សរុប |
| **កសិកម្ម** | | | |
| **ក.ដំណាំ** | | | |
| **- ដំណាំផ្លែ** | **២៤ម៉** | **៧២ម៉** | **៩៦ម៉** |
| • ត្រប់ | ៦ម៉ | ២០ម៉ | ២៦ម៉ |
| • ត្រសក់ | ៦ម៉ | ១៦ម៉ | ២២ម៉ |
| • ល្ពៅ | ៦ម៉ | ២០ម៉ | ២៦ម៉ |
| • ល្ហុង | ៦ម៉ | ១៦ម៉ | ២២ម៉ |
| **- ដំណាំដើម និងស្លឹក** | **៤៤ម៉** | **៨០ម៉** | **១២៤ម៉** |
| • ត្រកួន | ៦ម៉ | ១០ម៉ | ១៦ម៉ |
| • ស្ពៃក្រញាញ់ | ៦ម៉ | ១២ម៉ | ១៨ម៉ |
| • ខ្ទឹមស្លឹក | ៦ម៉ | ១២ម៉ | ១៨ម៉ |
| • ស្ពៃចង្កឹះ | ៦ម៉ | ១២ម៉ | ១៨ម៉ |
| • អំពៅ | ៨ម៉ | ១៤ម៉ | ២២ម៉ |
| • ផ្កា | ៦ម៉ | ១០ម៉ | ១៦ម៉ |
| • សណ្តែកបណ្តុះ | ៦ម៉ | ១០ម៉ | ១៦ម៉ |
| **- ដំណាំមើម** | **៦ម៉** | **២៤ម៉** | **៣០ម៉** |
| • ដំឡូងផ្វា | ៦ម៉ | ២៤ម៉ | ៣០ម៉ |
| **ខ.ការចិញ្ចឹម** | **១៨ម៉** | **៥៦ម៉** | **៧៤ម៉** |
| • មាន់ | ៦ម៉ | ១៦ម៉ | ២២ម៉ |
| • ត្រី | ៦ម៉ | ២៤ម៉ | ៣០ម៉ |
| • ជន្លេន | ៦ម៉ | ១៦ម៉ | ២២ម៉ |
| **សេវាកម្ម** | **៦ម៉** | **៥៤ម៉** | **៥០ម៉** |
| • ការរៀបចំសណ្តាប់ធ្នាប់ក្នុងគេហដ្ឋាននិងថ្នាក់រៀន | ២ម៉ | ១០ម៉ | ១២ម៉ |
| • ការបង្ហាញផ្លូវភ្ញៀវ | ២ម៉ | ២០ម៉ | ២២ម៉ |
| • ចេកហាល ( ចេកទុំ ) ដំណាប់ចេក | ២ម៉ | ១៤ម៉ | ១៦ម៉ |

| សិប្បកម្ម | ១០ម៉ | ៥៨ម៉ | ៦៨ម៉ |
|---|---|---|---|
| • អំបោសដើមកន្ទាំងបាយស ឬដើមព្រិច | ២ម៉ | ១០ម៉ | ១២ម៉ |
| • ទឹកខ្មេះធ្វើពីទឹកដូង ឬទឹកត្នោត | ២ម៉ | ១០ម៉ | ១២ម៉ |
| • បត់ក្រដាសបង្កើតរូបផ្សេងៗ | ២ម៉ | ១០ម៉ | ១២ម៉ |
| • បត់ក្រដាសធ្វើស្រោមសំបុត្រ | ២ម៉ | ៦ម៉ | ៨ម៉ |
| • ការធ្វើវត្ថុអនុស្សាវរីយ៍ពីវត្ថុផ្សេងៗ(សំបកស៊ុត សំបកខ្យង ខ្ចៅ ឬស្លឹកត្នោត...) | ២ម៉ | ២២ម៉ | ២៤ម៉ |

## ៣.បញ្ជីប្រធានបទថ្នាក់ទី៥

| ប្រធានបទ | ម៉ោង | | |
|---|---|---|---|
| | ទ្រឹស្តី | អនុវត្ត | សរុប |
| កសិកម្ម | | | |
| ក.ដំណាំ | | | |
| - **ដំណាំផ្លែ** | **២៤ម៉** | **៨០ម៉** | **១០៤ម៉** |
| • ឪឡឹក | ៦ម៉ | ២០ម៉ | ២៦ម៉ |
| • សណ្តែកបាយ | ៦ម៉ | ២០ម៉ | ២៦ម៉ |
| • ពោត | ៦ម៉ | ២០ម៉ | ២៦ម៉ |
| • ម្រះ | ៦ម៉ | ២០ម៉ | ២៦ម៉ |
| - **ដំណាំដើម និងស្លឹក** | **៣៤ម៉** | **៥៤ម៉** | **៨៨ម៉** |
| • ស្ពៃជើងទា | ៦ម៉ | ១២ម៉ | ១៨ម៉ |
| • ស្ពៃខៀវ | ៦ម៉ | ១២ម៉ | ១៨ម៉ |
| • ខាត់ណា | ៦ម៉ | ១២ម៉ | ១៨ម៉ |
| • ផ្សិតចំបើង | ៨ម៉ | ៨ម៉ | ១៦ម៉ |
| • ការបណ្តុះកូនឈើ | ៨ម៉ | ១០ម៉ | ១៨ម៉ |
| - **ដំណាំមើម** | **១២ម៉** | **២៨ម៉** | **៤០ម៉** |
| • ដៃថាវ | ៦ម៉ | ១៦ម៉ | ២២ម៉ |
| • ដំឡូងមី | ៦ម៉ | ១២ម៉ | ១៨ម៉ |
| **ខ.ការចិញ្ចឹមសត្វ** | **២០ម៉** | **៦០ម៉** | **៨០ម៉** |
| • ទា | ៦ម៉ | ១២ម៉ | ១៨ម៉ |
| • ជ្រូក | ៨ម៉ | ៣២ម៉ | ៤០ម៉ |

| | | | |
|---|---|---|---|
| • ទន្សាយ | ៦ម៉ | ១៦ម៉ | ២២ម៉ |
| **សេវាកម្ម** | **១០ម៉** | **៣២ម៉** | **៤២ម៉** |
| • ការរៀបផ្កាដាក់ថូ ឬ កន្ត្រក<br>• បដិសណ្ឋារកិច្ចចំពោះភ្ញៀវ<br>• ការលក់នំចំណី ឬ សម្ភារៈផ្សេងៗ | ៤ម៉<br>៤ម៉<br>២ម៉ | ១០ម៉<br>១២ម៉<br>១០ម៉ | ១៤ម៉<br>១៦ម៉<br>១២ម៉ |
| **សិប្បកម្ម** | **២៤ម៉** | **៦០ម៉** | **៨៤ម៉** |
| • គូរ កាត់ បិទ រូបពីក្រដាសពណ៌ធ្វើជារូបភាពផ្សេងៗ<br>• ត្បាញក្រដាសពណ៌<br>• គូរ កាត់ក្រដាសធ្វើជារូបធរណីមាត្រ (ការេ ត្រីកោណ ចតុកោណកែង...)<br>• ជ្រក់សណ្តែកបណ្តុះ<br>• ជ្រក់ត្រសក់<br>• ការផលិតប្រអប់ដាក់វត្ថុអនុស្សាវរីយ៍<br>• ការធ្វើវត្ថុអនុស្សាវរីយ៍ អំពីវល្លិ រពាក់ ស្លឹកត្នោត | ៤ម៉<br>៤ម៉<br>៤ម៉<br><br>២ម៉<br>២ម៉<br>៤ម៉<br>៤ម៉ | ១០ម៉<br>១០ម៉<br>១០ម៉<br><br>៤ម៉<br>៤ម៉<br>១០ម៉<br>១២ម៉ | ១៤ម៉<br>១៤ម៉<br>១៤ម៉<br><br>៦ម៉<br>៦ម៉<br>១៤ម៉<br>១៦ម៉ |

**៤.បញ្ជីប្រធានបទបច្ចេកទេសខ្លឹមសារថ្នាក់ទី៦**

| ប្រធានបទ | ម៉ោង | | |
|---|---|---|---|
| | ទ្រឹស្តី | អនុវត្ត | សរុប |
| **កសិកម្ម** | | | |
| **ក.ដំណាំ** | | | |
| - **ដំណាំផ្លែ** | **៣២ម៉** | **៨៨ម៉** | **១២០ម៉** |
| • ម្ទេសហាវ៉ៃ | ៤ម៉ | ១៦ម៉ | ២០ម៉ |
| • សណ្តែកកួរ | ៤ម៉ | ១៦ម៉ | ២០ម៉ |
| • សណ្តែកបារាំង | ៦ម៉ | ១៦ម៉ | ២២ម៉ |
| • ត្រឡាច | ៦ម៉ | ១២ម៉ | ១៨ម៉ |
| • ប៉េងប៉ោះ | ៦ម៉ | ១៦ម៉ | ២២ម៉ |
| • ននោង | ៦ម៉ | ១២ម៉ | ១៨ម៉ |
| - **ដំណាំដើម និងស្លឹក** | **១៨ម៉** | **៤៨ម៉** | **៦៦ម៉** |
| • សាលាដ | ៦ម៉ | ១២ម៉ | ១៨ម៉ |
| • ស្ពៃក្តោប | ៦ម៉ | ១៦ម៉ | ២២ម៉ |
| • ស្ពៃផ្កា | ៦ម៉ | ២០ម៉ | ២៦ម៉ |

| | | | |
|---|---|---|---|
| - **ដំណាំមើម** | **១២ម៉** | **៥២ម៉** | **៦៤ម៉** |
| • ខ្ទឹមបារាំង | ៦ម៉ | ២៦ម៉ | ៣២ម៉ |
| • ខ្ទឹមក្រហម | ៦ម៉ | ២៦ម៉ | ៣២ម៉ |
| **ខ.ការចិញ្ចឹមសត្វ** | **៤០ម៉** | **៩៤ម៉** | **១៣៤ម៉** |
| • គោ | ១០ម៉ | ១៨ម៉ | ២៨ម៉ |
| • ពពែ | ១០ម៉ | ១៤ម៉ | ២៤ម៉ |
| • កង្កែប | ៦ម៉ | ២៤ម៉ | ៣០ម៉ |
| • អន្ទង់ | ៦ម៉ | ២៤ម៉ | ៣០ម៉ |
| • ក្រួច | ៨ម៉ | ១៤ម៉ | ២២ម៉ |
| សេវាកម្ម | **២៦ម៉** | **៥៤ម៉** | **៨០ម៉** |
| • ការបត់កន្សែងបង្កើតជារូបផ្សេងៗ | ៦ម៉ | ១០ម៉ | ១៦ម៉ |
| • ការខាត់ស្បែកជើងឬបត់សំលៀកបំពាក់ | ២ម៉ | ៤ម៉ | ៦ម៉ |
| • ការលក់វត្ថុអនុស្សាវរីយ៍ | ២ម៉ | ៤ម៉ | ៦ម៉ |
| • ការក្រងភ្ញូងផ្កាម្លិះ | ២ម៉ | ៨ម៉ | ១០ម៉ |
| • ដំណាប់អំពិលទុំ | ២ម៉ | ៤ម៉ | ៦ម៉ |
| • ត្រីងៀត ( ត្រីរ៉ស់ ឬ ត្រីឆ្តោរ ) | ២ម៉ | ១០ម៉ | ១២ម៉ |
| • ការ៉េម | ៤ម៉ | ៨ម៉ | ១២ម៉ |
| • ការសិក្សាទីផ្សារ និងកំណត់ត្រាចំណូលចំណាយ | ៦ម៉ | ៦ម៉ | ១២ម៉ |
| សិប្បកម្ម | **២៨ម៉** | **១០០ម៉** | **១២៨ម៉** |
| • ការផលិតបង្គី | ២ម៉ | ១០ម៉ | ១២ម៉ |
| • ការផលិតជើងម៉ា | ២ម៉ | ១០ម៉ | ១២ម៉ |
| • ការផលិតម្ជូកស្លឹកត្នោត | ៤ម៉ | ១០ម៉ | ១៤ម៉ |
| • កាត់ក្រដាសផ្គុំធ្វើជារូបធរណីមាត្រ(ស៊ីឡាំង គូប ប្រលេពីប៉ែតកែង កោណ) | ៤ម៉ | ១២ម៉ | ១៦ម៉ |
| • ការផលិតស្មុកពីស្លឹកដូង ឬ ស្លឹកត្នោត | ២ម៉ | ១០ម៉ | ១២ម៉ |
| • ការផលិតទ្រនាប់កែវ ឬ ទ្រនាប់ចានបាយ ពីស្លឹកត្នោត ឬ ស្លឹកចាក | ២ម៉ | ១០ម៉ | ១២ម៉ |
| • ជ្រក់ត្រកួន | ២ម៉ | ២ម៉ | ៤ម៉ |
| • ការធ្វើវត្ថុអនុស្សាវរីយ៍ អំពីសំបកខ្យង គ្រំ ងាវ... | ៤ម៉ | ១៦ម៉ | ២០ម៉ |
| • ការផលិតទូពីផ្តៅ | ៦ម៉ | ២០ម៉ | ២៦ម៉ |

# ផ្នែកទី២
# សេចក្តីណែនាំអនុវត្តកម្មវិធីសិក្សាលម្អិត
# បំណិនជីវិតតាមមូលដ្ឋាន

## ១.ការជ្រើសរើសប្រធានបទបំណិនជីវិត និង ការកសាងម៉ូឌុល

### ក. ការជ្រើសរើសប្រធានបទ

សាលារៀនត្រូវធ្វើការពិចារណា ប៉ាន់ប្រមាណ និងសិក្សាវាយតម្លៃលើតម្រូវការធនធានមនុស្ស ថវិកា សម្ភារៈ សក្តានុពលនិងពេលវេលារបស់សាលារៀនដែលអំណោយផលសម្រាប់ការអនុវត្តដល់សាលារៀននិងការចូលរួមរបស់សហគមន៍ ដើម្បីជ្រើសរើសប្រធានបទជំនាញដែលមាននៅក្នុងបញ្ជីប្រធានបទនៃកម្មវិធីសិក្សាលម្អិតបំណិនជីវិតតាមមូលដ្ឋានសម្រាប់ថ្នាក់ទី៤ ទី៥ និងទី៦ ឬអាចជ្រើសរើសប្រធានបទផ្សេងមកបង្រៀនសិស្សក៏បានទៅតាមលទ្ធភាពរបស់សាលារៀន និងសហគមន៍ ។ ការជ្រើសរើសនេះគួរតែមានការចូលរួមពីតំណាងសិស្ស មាតាបិតាសិស្ស និង អ្នកពាក់ព័ន្ធនានា ។

ការជ្រើសរើសប្រធានបទសម្រាប់ថ្នាក់នីមួយៗក្នុងមួយឆ្នាំសិក្សាយ៉ាងតិច៧៦ម៉ ។ ខាងក្រោមនេះជាឧទាហរណ៍នៃការជ្រើសរើសប្រធានបទ៖

| ថ្នាក់ទី | ប្រធានបទ | ម៉ោងសិក្សា | ម៉ោងសិក្សាសរុប |
|---|---|---|---|
| ៤ | • ដំណាំត្រកួន<br>• ការចិញ្ចឹមមាន់<br>• ការបង្ហាញផ្លូវភ្ញៀវ<br>• ការធ្វើអំបោសពីដើមកន្ទាំងបាយស ឬដើមព្រិច<br>• ការបត់ក្រដាសបង្កើតជារូបផ្សេងៗ | ១៦ម៉<br>២២ម៉<br>២២ម៉<br>១២ម៉<br><br>៦ម៉ | ៧៨ម៉ |
| ៥ | • ស្តែជើងទា<br>• ការផលិតប្រអប់ដាក់វត្ថុអនុស្សាវរីយ៍<br>• ការចិញ្ចឹមជ្រូក<br>• ជ្រក់ត្រសក់ | ១៨ម៉<br>១៤ម៉<br>៤០ម៉<br>៦ម៉ | ៧៨ម៉ |
| ៦ | • ដំណាំប៉េងប៉ោះ<br>• ការចិញ្ចឹមកង្កែប<br>• ការធ្វើវត្ថុអនុស្សាវរីយ៍ពីសំបកខ្យង គ្រំ ងាវ...<br>• ដំណាប់អំពិលទុំ | ២២ម៉<br>៣០ម៉<br>២០ម៉<br><br>៦ម៉ | ៧៨ម៉ |

បញ្ជីប្រធានបទនៅក្នុងឯកសារកម្មវិធីសិក្សាលម្អិតបំណិនមូលដ្ឋាននិងសេចក្តីណែនាំអនុវត្តន៍សម្រាប់ថ្នាក់ទី៤ ដល់ ទី៦នេះ មានប្រធានបទមួយចំនួនបានចងក្រងជាម៉ូឌុល រួចហើយដោយក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយអង្គការន័រវេស្សន៍

សង្គ្រោះកុមារដូចជាប្រធានបទផ្នែកកសិកម្ម(ដំណាំត្រប់ ត្រសក់ សណ្តែកកួរ ត្រកួន ស្ពៃក្តោប ស្ពៃជើងទា ស្ពៃក្រញាញ់ ស្ពៃចង្កឹះ ននោង ឃ្លោក ត្រឡាច ឆៃថាវ ល្ពង អំពៅ ម្ទេស ចិញ្ចឹមទា មាន់ ជ្រូក ត្រី...) ។ ចំពោះប្រធានបទជំនាញដែលបានជ្រើសរើស ហើយមិនទាន់បាន ចងក្រងជាម៉ូឌុល សាលារៀនគួរតែចងក្រងជាម៉ូឌុល មុននឹងយកទៅបង្រៀន ។

**ខ. ការកសាងម៉ូឌុល**

តើម៉ូឌុលជាអ្វី ? ម៉ូឌុលគឺជាពាក្យខ្ចី មកពីភាសាបរទេស ( Module ) ។ នៅក្នុងឯកសារនេះ ពាក្យម៉ូឌុលត្រូវបានគេសម្គាល់លើឯកសារដែលបង្ហាញនូវខ្លឹមសារបច្ចេកទេសរបស់ប្រធានបទជំនាញណាមួយ ។

ដូចនេះការកសាងម៉ូឌុលគឺជាការចងក្រងខ្លឹមសារបច្ចេកទេសសម្រាប់ការអនុវត្តជំនាញ ។ វិសាលភាពខ្លឹមសាររបស់ម៉ូឌុលអាស្រ័យទៅលើវត្ថុបំណង និង ទម្រង់ដែលបានកំណត់។ការកសាងម៉ូឌុលត្រូវធ្វើឱ្យមានលក្ខណៈរួមដោយ ផ្តល់ខ្លឹមសារ បច្ចេកទេសដល់អ្នកអានឱ្យងាយយល់ និង អាចយកទៅអនុវត្តបាន។ ម៉ូឌុលអាចត្រូវ បាន កសាងដោយអ្នកពាក់ព័ន្ធដូចជា គ្រូបង្រៀន គណៈកម្មការសាលារៀន គណៈកម្មការសហគមន៍ ក្រុមសិស្ស អង្គការនានា ក្រសួងអប់រំ យុវជន និងកីឡា...។

តាមបទពិសោធការកសាងម៉ូឌុលរបស់សាលារៀនចំណោះទូទៅ កន្លងមកភាគច្រើនអនុវត្តជាពីរដំណាក់ គឺដំណាក់ប្រមូលព័ត៌មាន និង ដំណាក់សរសេរម៉ូឌុល។

**ក. ដំណាក់ប្រមូលព័ត៌មាន**

នៅក្នុងដំណាក់នេះ អ្នកពាក់ព័ន្ធក្នុងការកសាងម៉ូឌុលត្រូវជួបពិគ្រោះយោបល់ និងកត់ត្រាទុកជាសេចក្តីព្រាងនូវខ្លឹមសារ ដែលទទួលបានពីអ្នកបច្ចេកទេស ការស្រាវជ្រាវឯកសារនានា ឬ ការអនុវត្តសាកល្បង ។

**ខ. ដំណាក់សរសេរម៉ូឌុល**

បន្ទាប់ពីទទួលបាននូវព័ត៌មានដែលជាខ្លឹមសារបច្ចេកទេសលើប្រធានបទ ខ្លឹមសារទាំងនោះ នឹងត្រូវប្រើប្រាស់ចងក្រងជាម៉ូឌុល ដោយរៀបចំទៅតាមលំដាប់លំដោយនៃលទ្ធផលសិក្សារបស់ប្លង់ម៉ូឌុលដែលបានកំណត់ដូចខាងក្រោម៖

ប្រធានបទ ការដាំដំណាំ

- រយៈពេលសិក្សាទ្រឹស្តី៖........................................
- រយៈពេលអនុវត្ត ៖........................................
- ពេលវេលាសមស្រប ៖........................................
- វត្ថុបំណងមេរៀន ៖........................................

| ខ្លឹមសារ | លទ្ធផលសិក្សា |
|---|---|
| **I.ដំណាក់រៀបចំ** | |
| ១.ឧបករណ៍និងសម្ភារៈ | • ប្រាប់ពីឧបករណ៍ និងសម្ភារៈដែលត្រូវ ប្រើប្រាស់ |
| ២.ការជ្រើសរើសពូជ | • ជ្រើសរើសពូជបានត្រឹមត្រូវយកទៅដាំដើម្បីទទួលបានទិន្នផលខ្ពស់។ |
| ៣.ដីសមស្របសម្រាប់ដំណាំ | • ប្រាប់ពីប្រភេទដីដែលអំណោយផលសម្រាប់ការដាំ។ |
| **II.ដំណាក់អនុវត្ត** | |
| ១.វិធីធ្វើរងដំណាំ/ធ្វើដី | • ប្រាប់ពីវិធីធ្វើដី រងដំណាំសម្រាប់ដាំ។ |
| ២.វិធីដាំ | • រៀបរាប់ពីរបៀបដាំដំណាំតាមលក្ខណៈបច្ចេកទេស។ |
| ៣.ការថែទាំ | • រៀបរាប់ពីការថែទាំ និងការលូតលាស់នៃដំណាំ<br>• រៀបរាប់ពីការប្រើប្រាស់ជី និងទឹកសម្រាប់ការលូតលាស់<br>• រៀបរាប់ពីប្រភេទនៃជំងឺដែលប៉ះពាល់ដល់ការលូតលាស់ និងវិធីបង្ការជំងឺ និងសត្វចង្រៃ។ |
| ៤.ការប្រមូលផល | • កំណត់ពេលវេលា និងរបៀបដែលត្រូវប្រមូលផល<br>• រៀបរាប់ពីវិធីរក្សាទុកផលដំណាំ |
| ៥.ផលប្រយោជន៍ និងតម្រូវការ | រៀបរាប់ពីអត្ថប្រយោជន៍នៃដំណាំចំពោះសុខភាព។<br>• ប្រាប់ពីតម្រូវការទីផ្សារ និងការប្រើប្រាស់<br>• រៀបរាប់ពីផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចដែលផ្តល់ចំពោះអ្នកផលិត<br>• បណ្តុះស្មារតីសិស្សឱ្យយល់ដឹងពីផលប៉ះពាល់នៃការប្រើប្រាស់ជីគីមី និងថ្នាំពុលមិនត្រឹមត្រូវ ចំពោះបរិស្ថានធម្មជាតិ និងសុខភាពមនុស្ស។<br>• ប្រាប់ពីវិធីបង្ការគ្រោះថ្នាក់ដែលកើតមានក្នុងពេលអនុវត្ត។ |

## ២. ការរៀបចំកាលវិភាគ

កម្មវិធីសិក្សាកម្រិតអប់រំនៅបឋមសិក្សាបានផ្តល់ដល់សិស្សនូវពុទ្ធិបំណិនជីវិតតាមមូល ដ្ឋាន(បំណិនបុរេវិជ្ជាជីវៈ បំណិនអាជីព )និង តម្លៃអប់រំមូលដ្ឋាន។ កម្មវិធីសិក្សានៅកម្រិតបឋមសិក្សានេះចែកចេញជាកម្មវិធីសិក្សាជាតិ និងកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន។

### កម្រិតបឋមសិក្សា

| កម្មវិធីសិក្សាជាតិ | កម្មវិធីសិក្សាបំណិនជីវិត | ម៉ោងសរុប |
|---|---|---|
| ៥ម៉ោងសិក្សាក្នុង ១ថ្ងៃ។ ១ម៉ោងសិក្សាមាន ៤០នាទី | ២ម៉ោងទៅ ៥ម៉ោងសិក្សាក្នុងមួយសប្តាហ៍ ដែល១ម៉ោងសិក្សាមាន៤០នាទី។ | ២៧ម៉ោងសិក្សា ទៅ ៣០ម៉ោងសិក្សា ក្នុងមួយសប្តាហ៍។ |

ផ្អែកទៅតាមគោលនយោបាយសម្រាប់អភិវឌ្ឍកម្មវិធីសិក្សាចំណេះទូទៅ ២០០៥-២០០៩ ម៉ោងសម្រាប់កម្មវិធីបំណិនជីវិតតាមមូលដ្ឋានបឋមសិក្សាមានពី ២ម៉ោងសិក្សាទៅ៥ម៉ោងសិក្សាក្នុងមួយសប្តាហ៍។

ដូចនេះចំនួនម៉ោងបង្រៀនបំណិនជីវិតនៅកម្រិតបឋមសិក្សាមាន ៧៦ម៉ោង ក្នុងមួយឆ្នាំសិក្សា( ២ម៉ោងសិក្សាក្នុងមួយសប្តាហ៍ × ៣៨សប្តាហ៍ ) ក្នុងករណីសាលារៀនមានធនធាន មានលទ្ធភាព គណៈគ្រប់គ្រងសាលារៀនអាចបន្ថែមម៉ោងបង្រៀនបំណិនជីវិតតាមមូលដ្ឋានលើសពី ២ម៉ោងសិក្សា ( ចន្លោះពី ២ម៉ ទៅ៥ម៉) ។

ផ្អែកតាមកាលវិភាគដែលធ្លាប់អនុវត្តកន្លងមកការបង្រៀនបំណិនជីវិតតាមមូលដ្ឋានច្រើនបង្រៀនតែថ្ងៃព្រហស្បតិ៍ ប៉ុន្តែការបង្រៀនកម្មវិធីបំណិនតាមមូលដ្ឋាននៅកម្រិតបឋមសិក្សាមិនតម្រូវឱ្យរៀនតែក្នុងថ្ងៃព្រហស្បតិ៍ទេ។ គណៈគ្រប់គ្រងសាលាអាចរៀបចំកាលវិភាគសម្រាប់បង្រៀនកម្មវិធីនេះនៅថ្ងៃណាមួយក៏បាន។

ដើម្បីកំណត់ម៉ោងក្នុងកាលវិភាគ គណៈគ្រប់គ្រងសាលាត្រូវយកម៉ោងសរុបរវាងម៉ោងទ្រឹស្តីនិងម៉ោងអនុវត្តប្រធានបទទាំងអស់ដែលសាលាជ្រើសរើសយក រួចចែកម៉ោងតាមកាលវិភាគសិក្សាជាមួយមុខវិជ្ជាសិក្សាគោលដទៃទៀត។

សម្រាប់ម៉ោងបង្រៀនប្រធានបទណាមួយដែលមានកំណត់ក្នុងកម្មវិធីសិក្សាលម្អិតមិនមែនមានន័យថា គ្រូត្រូវអនុវត្តតាមដាច់ខាតនោះទេ ប៉ុន្តែគ្រូអាចសម្របសម្រួលរវាងម៉ោងអនុវត្ត និង ម៉ោងទ្រឹស្តី ។

ឧទាហរណ៍៖ ក្នុងកម្មវិធីសិក្សាលម្អិតប្រធានបទមួយបានកំណត់ម៉ោងទ្រឹស្តី ៤ម៉ ម៉ោងអនុវត្ត១០ម៉។ គ្រូអាចបន្ថយ ឬបន្ថែមម៉ោងទ្រឹស្តី និងម៉ោងអនុវត្តដោយលៃយ៉ាងណាឱ្យបានម៉ោងសរុបរវាងទ្រឹស្តី និង អនុវត្តនៅ ១៤ម៉ដដែល។

ការសិក្សាមេរៀនផ្នែកកសិកម្ម ម៉ោងនៅផ្នែកអនុវត្តដែលមានក្នុងកម្មវិធីសិក្សាលម្អិតបំណិនជីវិតតាមមូលដ្ឋាន បានកំណត់ម៉ោងជាក់លាក់។ ឧទាហរណ៍៖ ការដាំប៉េងប៉ោះមានម៉ោងអនុវត្ត ១៦ម៉ មានន័យថាក្នុងរយៈពេល១៦ម៉នេះ មិនបានរាប់បញ្ចូលការងារថែទាំជាប្រចាំដូចជាការស្រោចទឹករាល់ថ្ងៃនោះទេ គឺសម្រាប់តែការរៀបចំដី ការដាំ ការធ្វើស្នៅ ការជ្រំដី ការដាក់ជី ការសង្កេតតាមដានការលូតលាស់ និង ការប្រមូលផលប៉ុណ្ណោះ ។

## ៣. វិធីសាស្ត្របង្រៀន និង ដំណើរការបង្រៀន

### ក. វិធីសាស្ត្របង្រៀន

នៅក្នុងការសិក្សាបំណិនជីវិតតាមមូលដ្ឋាន គឺតម្រូវឱ្យសិស្សសិក្សាទ្រឹស្តីជាមុនបន្ទាប់មកយកទ្រឹស្តីទៅអនុវត្តជាក់ស្តែង ដោយផ្សារភ្ជាប់ការសិក្សាទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃ ដើម្បីឱ្យពួកគេមានជំនាញ និងសមត្ថភាពពិតប្រាកដ ។ វិធីសាស្ត្រដែលគួរជ្រើសរើសក្នុងការបង្រៀន មានដូចជាៈ

ប្រើគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀន និងរៀនដើម្បីបង្ហាញ កសាង និងពង្រឹងចំណេះដឹងរបស់អ្នកសិក្សាដែលមានស្រាប់ ជំរុញការសិក្សាបែបសកម្ម ដោយធ្វើការងារជាបុគ្គល ការងារជាដៃគូ ការងារជាក្រុម និង ការស្រាវជ្រាវ តាមរយៈការអាន ការធ្វើទស្សនកិច្ចសិក្សា ការពិសោធ ការទស្សនាទូរទស្សន៍ ល្បែងសិក្សា ... ។

### ខ. ដំណើរការបង្រៀន

ដំណើរការបង្រៀន និងរៀនបំណិនជីវិតតាមមូលដ្ឋានសម្រាប់ថ្នាក់ទី៤ដល់ទី៦មានពីរផ្នែក គឺការបង្រៀនទ្រឹស្តី និងការអនុវត្ត។

**ការបង្រៀនទ្រឹស្តី៖** គ្រូគប្បីសម្របសម្រួលសិស្សឱ្យយល់ពីតម្រូវការរបស់មនុស្សម្នាក់ៗ ផលប៉ះពាល់ និងផលប្រយោជន៍ក្នុងការរស់នៅប្រចាំថ្ងៃសម្រាប់គ្រួសារ និងសហគមន៍។

ក្នុងការបង្រៀនខ្លឹមសារមេរៀនគ្រូគប្បីបង្កលក្ខណៈឱ្យសិស្សគិត វិភាគ ពិភាក្សារកដំណោះស្រាយ ឱ្យបានច្រើនដើម្បីឱ្យសិស្សទទួលបានចំណេះដឹង និងសមត្ថភាពគ្រប់ជ្រុងជ្រោយ។

ការបង្រៀនអាចធ្វើសកម្មភាពដូចខាងក្រោម៖

- ការសួរសំណួរ
- ការបញ្ចេញគំនិត ឬព្យុះគំនិត
- ការសង្កេត ការស្រាវជ្រាវ (លើរូបភាព ឬវត្ថុជាក់ស្តែង )
- ការអានអត្ថបទ ( បច្ចេកទេស )
- ការពិភាក្សាក្រុម ( ក្រុមតូច ក្រុមធំ )

- o ការសន្និដ្ឋាន
- o ការធ្វើផែនការ ឬគម្រោង ( ការប្រមូលព័ត៌មាន ការជ្រើសរើសពូជ ការជ្រើសរើសដី ទីកន្លែង ពេលវេលា សម្ភារៈ កម្លាំងថែទាំ)
- o ការផ្តល់ខ្លឹមសារមេរៀនទាក់ទងនឹងបច្ចេកទេស(ការជ្រើសរើសពូជ ការរៀបចំដី របៀបដាំ ការថែទាំ និងគ្រប់គ្រង វិធីបង្ការជំងឺ និងសត្វល្អិតចង្រៃ ការប្រមូលផល វត្ថុធាតុដើម របៀបផលិត សារប្រយោជន៍ )។

**ការអនុវត្តៈ** ការអនុវត្តជាសកម្មភាពដែលត្រូវយកចំណេះដឹងបានមកពីការសិក្សាទ្រឹស្តី ទៅអនុវត្តជាក់ស្តែង ។ ការអនុវត្តនេះមានសកម្មភាពសំខាន់ពីរ ៖

- សកម្មភាពអនុវត្តជាក់ស្តែង ( ឧ. ការដាំ ការចិញ្ចឹម ការផលិត... )
- សកម្មភាពចងក្រងបទពិសោធន៍ធ្វើជាឯកសារ ។

**សកម្មភាពអនុវត្តជាក់ស្តែង**

មុននឹងអនុវត្តជាក់ស្តែង គ្រូណែនាំសិស្សឱ្យពិភាក្សាគ្នា ដើម្បីធ្វើតារាងផែនការអនុវត្តជាក់ស្តែងដែលមានដូចឧទាហរណ៍ខាងក្រោម ៖

ការដាំគ្រប់

| ល.រ | សកម្មភាព | អ្នកទទួលខុសត្រូវ | អ្នកចូលរួម | ថវិកា | ពេលវេលា | ទីកន្លែង |
|---|---|---|---|---|---|---|
| ១. | ពូជ | ឈ្មោះសិស្ស៥នាក់ | គ្រូ និង សហគមន៍ | តម្លៃ | ថ្ងៃទី....ខែ...ឆ្នាំ | ផ្ទះ ឬផ្សារ... |
| ២. | ដី | គ្រូ នាយក សហគមន៍ | គ្រូ នាយក សហគមន៍ | តម្លៃ | ថ្ងៃទី....ខែ...ឆ្នាំ | ក្នុងសាលាឬ សហគមន៍ |
| ៣. | ឧបករណ៍ប្រើប្រាស់ | សិស្ស គណៈគ្រប់គ្រង | សហគមន៍ | តម្លៃ | ថ្ងៃទី....ខែ...ឆ្នាំ | ផ្ទះឬ សាលារៀន.. |
| ៤. | រៀបចំដី | សិស្សទូទាំងថ្នាក់ទី.... | គ្រូ នាយក សហគមន៍ | តម្លៃ | ថ្ងៃទី....ខែ...ឆ្នាំ | ក្នុងសាលាឬ សហគមន៍ |
| ៥. | ដាំ និងថែទាំ | សិស្សទូទាំងថ្នាក់ទី.... | គ្រូ សហគមន៍ | តម្លៃ | ថ្ងៃទី....ខែ...ឆ្នាំ | ក្នុងសាលាឬ សហគមន៍ |
| ... | ...... | | | | | |

**សកម្មភាពចងក្រងបទពិសោធន៍ ធ្វើជាឯកសារ**

គ្រូត្រូវដឹកនាំសិស្សឱ្យរកទម្រង់នៃការចងក្រងបទពិសោធន៍ដើម្បីទុកជាឯកសារ ។ ការរៀបចំនេះត្រូវធ្វើតាមក្រុមដែលបានអនុវត្តជាក់ស្តែងទៅលើប្រធានបទណាមួយ ឧទាហរណ៍៖ ក្រុមទី ១ ដាំត្រកួន ក្រុមទី២ ដាំស្ពៃខៀវ ដោយសរសេររាល់ចំណុចទាំងឡាយដែលក្រុមខ្លួនបានអនុវត្តរហូតដល់ទទួលផល(ការរៀបចំដី ការរើសពូជ ការដាំ ការប្រើប្រាស់ជី ការថែទាំ ការប្រមូលផល...)។ គ្រូពិនិត្យ និងដាក់ពិន្ទុ ព្រមទាំងផ្សព្វផ្សាយបន្តនៅកន្លែងផ្សេងៗ ដូចជាយកទៅដាក់ក្នុងបណ្ណាល័យជាដើម។

## ៤. ការវាយតម្លៃ

ការវាយតម្លៃ គឺជាការវាស់ចំណេះដឹង ចំណេះធ្វើនិងឥរិយាបថរបស់សិស្សក្រោយពីសិស្សបានសិក្សារួច ហើយក៏ជាការឆ្លុះបញ្ចាំងការបង្រៀនរបស់គ្រូ និង ជួយគ្រូក្នុងការបង្រៀនសិស្សឱ្យទទួលបានលទ្ធផលល្អ។ការវាយតម្លៃក្នុងកម្មវិធីបំណិនជីវិតតាមមូលដ្ឋានសម្រាប់បឋមសិក្សានេះគ្រូវាយតម្លៃទៅលើទ្រឹស្តី ការអនុវត្ត និងលើឥរិយាបថ។

### ៤.១. លើទ្រឹស្តី

ការវាយតម្លៃលើទ្រឹស្តីគឺជាការវាស់កម្រិតយល់ដឹងរបស់សិស្សផ្អែកទៅតាមខ្លឹមសារមេរៀនដែលរៀននៅក្នុងថ្នាក់។ប្រភេទសំណួរសម្រាប់វាយតម្លៃលើទ្រឹស្តី ត្រូវបានរៀបចំឡើងដោយគ្រូ និងមានការចូលរួមពិនិត្យពីប្រធានក្រុមបច្ចេកទេសកម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋាន ។

### ៤.២. លើការអនុវត្ត

ការវាយតម្លៃលើការអនុវត្តគឺជាការវាស់ស្ទង់លើសកម្មភាពអនុវត្តផ្ទាល់ដោយផ្អែកលើលទ្ធផលស្នាដៃសិស្សតាមប្រភេទប្រធានបទដែលពួកគេកំពុងអនុវត្តនិងអនុវត្តរួច ។

### ៤.៣.លើឥរិយាបថ

ការវាយតម្លៃលើឥរិយាបថគឺជាការវាយតម្លៃដោយសង្កេតលើចំណុចសំខាន់ៗដូចខាងក្រោម៖

- ការប្រាស្រ័យទាក់ទង
- ការវិភាគល្អិតល្អន់
- ដំណោះស្រាយបញ្ហា
- ការសហការ
- ការធ្វើសេចក្តីសម្រេចចិត្ត
- ការកំណត់គោលដៅ
- ការចូលរួម...។